SUPREME JUDICIAL COURT
BOSTON, MASSACHUSETTS 02108

# កំណត់សំគាល់: លោក-អ្នកប្រហែលជាអាចលុបចោលការផ្តន្ទាទោស រឿងថ្នាំញៀនពាក់ព័ន្ធនឹងអ្នកស្រី Dookhan ចេញពីបញ្ជីរបស់លោក-អ្នក

អាស័យដ្ឋាន
អាស័យដ្ឋាន
អាស័យដ្ឋាន

6 មិថុនា 2017

ជូនចំពោះ ____________:

ខ្ញុំជាចៅក្រមម្នាក់នៃតុលាការកំពូលដែលជាតុលាការខ្ពស់បំផុតនៅក្នុងរដ្ឋម៉ាស្សាជូសេត្ស៍។ តុលាការបានកំណត់ថា លោក-អ្នកប្រហែលជាត្រូវបានគេផ្តន្ទាទោសដោយខុសច្បាប់ពីបទឧក្រិដ្ឋគ្រឿងញៀនមួយ ឬច្រើនដោយសារតែការប្រព្រឹត្តមិនត្រឹមត្រូវដោយគីមីវិទូអានី្ន ដូក្ខាន (Annie Dookhan) ។ ឯកសារតុលាការបង្ហាញថា អ្នកស្រី Dookhan បានពិសោធគ្រឿងញៀនខ្លះ ឬទាំងអស់នៅក្នុងករណីនានាដូចខាងក្រោមដែលលោក-អ្នកត្រូវបានគេផ្តន្ទាទោសៈ

[ - Insert cases ]

**ដោយសារតែកំហុសវិជ្ជាជីវៈរបស់អ្នកស្រី Dookhan, លោក-អ្នកមានសិទ្ធិពិសេសដើម្បីដេញដោលការផ្តន្ទាទោសថ្នាំទាំងនោះ និងប្រហែលជាអាចលុបចោលការផ្តន្ទាទោសទាំងនោះចេញពីបញ្ជីបទឧក្រិដ្ឋរបស់អ្នក។** តុលាការនេះមានការព្រួយបារម្ភអំពីភាពយុត្តិធម៌នៃការផ្តន្ទាទោសទាំងនោះ និងចង់ធានាថាយុត្តិធម៌ត្រូវតែមាន។

ការលុបចោលការផ្តន្ទាទោសមួយពីបញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នកអាចផ្តល់នូវអត្ថប្រយោជន៍សំខាន់ដល់លោក-អ្នកទាក់ទងទៅនឹងការងារ, លំនៅដ្ឋាន, អន្តោប្រវេសន៍ និងច្រើនទៀត។ សំណុំឯកសារពីតុលាការនេះមានព័ត៌មានពីសិទ្ធិផ្នែកផ្លូវច្បាប់ និងជម្រើសរបស់លោក-អ្នក រួមទាំងសំបុត្រមួយច្បាប់ពីគណៈមេធាវីសាធារណៈសំរាប់ចុងចោទរដ្ឋម៉ាស្សាជូសេត្ស៍ ដែលហៅថាគណៈកម្មាធិការសម្រាប់សេវាកម្មមេធាវីសាធារណៈ។

លោក-អ្នកប្រហែលជាបានទទួលសំបុត្រមួយច្បាប់ពីសំណុំរឿងរបស់លោក-អ្នកនៅខែកញ្ញា ប៉ុន្តែសំបុត្រនោះមិនមែនមកពីតុលាការទេ។

បើលោក-អ្នកមានសំណួរអ្វី ខ្ញុំជំរុញឱ្យលោក-អ្នកទូរស័ព្ទទៅទូរស័ព្ទបន្ទាន់គណៈមេធាវីសាធារណៈលេខ **888-999-2881**, ឬនៅគេហទំព័រ **www.mass.gov/courts/druglab**.

ដោយសេចក្តីរាប់អាន,

[ហត្ថលេខា-អេឡិចត្រូនិក ]
សហការីចៅក្រមតុលាការកំពូល

**ក្នុងសំណុំឯកសារនេះ:**

(1) កំណត់សំគាល់ពីសិទ្ធិរបស់លោក-អ្នក
(2) លិខិតការណែនាំផ្នែកច្បាប់ពីមេធាវីសាធារណៈ

# សិទ្ធិរបស់លោក-អ្នក

4. **លោក-អ្នកមានសិទ្ធិរកមេធាវី**

   លោក-អ្នកមានសិទ្ធិទទួលដំបូន្មានពីមេធាវីម្នាក់អំពី ថាតើគួរតែដេញដោលការផ្តន្ទាទោសទាំងនោះ ឬអត់។ បើលោក-អ្នកសម្រេចថាទៅតុលាការ លោក-អ្នកមានសិទ្ធិឱ្យមានមេធាវីម្នាក់ធ្វើជាតំណាងលោក-អ្នក។ បើលោក-អ្នកមិនមានលទ្ធភាពជួលមេធាវីម្នាក់បានទេ គេនឹងតែងតាំងមេធាវីម្នាក់ឱ្យជួយផ្តល់យោបល់ និងជាតំណាងលោក-អ្នកដោយឥតគិតថ្លៃ។

5. **លោក-អ្នកមានសិទ្ធិស្នើឱ្យតុលាការលុបចោលការផ្តន្ទាទោសរបស់លោក-អ្នក**

   **លោក-អ្នកនឹងមិនចាំបាច់បង្ហាញថា Annie Dookhan បានធ្វើខុសចំពោះការធ្វើតេស្តថ្នាំញៀនក្នុងសំណុំរឿងរបស់លោក-អ្នកទេ។ ចៅក្រមនឹងសន្និដ្ឋានថា គាត់បានធ្វើមែន។ នេះគេហៅថា "ការសន្និដ្ឋានរួម" ដែលអ្នកស្រី Dookhan បានប្រព្រឹត្តិខុសយ៉ាងធ្ងន់ធ្ងរនៅក្នុងសំណុំរឿងរបស់អ្នក។**

   **បើលោក-អ្នកបានសារភាពកំហុស**, អ្នកមានសិទ្ធិដកពាក្យទទួលកំហុសរបស់អ្នកវិញ។ ដើម្បីធ្វើយ៉ាងនេះបាន លោក-អ្នកត្រូវតែបង្ហាញនូវ "ភវនីយភាពសមហេតុផល" ដែលថា អ្នកនឹងមិនសារភាពកំហុសឡើយ បើអ្នកបានដឹងអំពីកំហុសរបស់អ្នកស្រី Dookhan ។

   **បើលោក-អ្នកត្រូវបានគេរកឃើញថាមានទោសក្នុងពេលវិនិច្ឆ័យ** លោក-អ្នកមានសិទ្ធិសុំឱ្យមានការវិនិច្ឆ័យជាថ្មីបាន។ ចៅក្រមនឹងពិនិត្យមើលករណីរបស់លោក-អ្នក។ ចៅក្រមនឹងផ្តល់ឱ្យមានការវិនិច្ឆ័យជាថ្មីមួយបាន លុះត្រាតែចៅក្រមបានសម្រេចថា ការវិភាគថ្នាំរបស់អ្នកស្រី Dookhan មិនមានឥទ្ធិពលអ្វីលើគណៈវិនិច្ឆ័យ ឬមានការបះទង្គិចស្តួចស្តើងណាស់។

6. **បើលោក-អ្នកដេញដោលការផ្តន្ទាទោសរបស់លោក-អ្នក ហើយបានជោគជ័យ លោក-អ្នកមានសិទ្ធិទទួលការវិនិច្ឆ័យសារជាថ្មី**

   បើលោក-អ្នកដេញដោលការផ្តន្ទាទោសរឿងថ្នាំញៀនរបស់លោក-អ្នក ហើយការដេញដោលនោះបានជោគជ័យ ចៅក្រមនឹងដកវិញ្ញ "លុបចោល" នូវការផ្តន្ទាទោសរបស់លោក-អ្នក។ ពេលដែលការផ្តន្ទាទោសរបស់លោក-អ្នកនោះត្រូវគេលុបចោល:

   - រដ្ឋអាជ្ញាមិនអាចបន្ថែមការចោទប្រកាន់ថ្មី ឬនាំយកការចោទប្រកាន់ចាស់ណាដែលត្រូវកាត់បន្ថយរួច ឬត្រូវបានជំរុះចោលពីដំបូលរួចទៅហើយនោះមកវិញបានឡើយ។
   - បើលោក-អ្នកទទួលការវិនិច្ឆ័យម្តងទៀត មានតែសេចក្តីសម្រេចពេលវិនិច្ឆ័យនេះទេដែលសម្រេចថាលោក-អ្នកមាន ឬក៏ឥតមានទោស។ បើលោក-អ្នកត្រូវគេរកឃើញថាមានទោស តុលាការមិនអាចដាក់ទណ្ឌកម្មដទៃណាបន្ថែមពីលើអ្វីដែលលោក-អ្នកទទួលបានពីការវិនិច្ឆ័យចុងក្រោយនោះឡើយ។ គេមិនអាចដាក់ទោសលោក-អ្នកឱ្យជាប់ឃុំ ស្ថិតក្រោមអាជ្ញាអង្កេត ឬពិន័យជាប្រាក់បន្ថែមបានឡើយ។

# ជំហ៊ានបន្ទាប់

វាអាស្រ័យលើលោក-អ្នកខ្លួនឯងផ្ទាល់ដើម្បីសម្រេច ថាតើលោក-អ្នកចង់ធ្វើអ្វីនៅជំហ៊ានបន្ទាប់។

- បើលោក-អ្នកមិនធ្វើអ្វីទេ ការផ្តន្ទាទោសដែលគេរាយក្នុងសំបុត្រពីតុលាការនឹងនៅក្នុងបញ្ជីបទឧក្រិដ្ឋរបស់លោក-អ្នក។
- លោក-អ្នកអាចពិភាក្សាជាមួយមេធាវីម្នាក់ដើម្បីសម្រេច ថាតើលោក-អ្នកចង់តវ៉ាដេញដោលការផ្តន្ទាទោសទាំងនោះ ឬអត់។

## របៀបរកមេធាវីម្នាក់:

A. **<u>បើសិនជាលោក-អ្នកមិនអាចលៃលកជួលមេធាវីម្នាក់បាន</u>**, លោក-អ្នកមានសិទ្ធិមួយដើម្បីឱ្យតុលាការតែងតាំងមេធាវីម្នាក់ឱ្យអ្នកបាន។ ចូរប្រើប្រាស់វិធានការដូចខាងក្រោមដើម្បីទាក់ទង CPCS, ជាស្ថាប័នជួយការពារចុងចោទសាធារណៈក្នុងរដ្ឋម៉ាស្សាជូសេត្ស៍ ដើម្បីចាប់ផ្តើមដំណើរការ:

1. តាមទូរស័ព្ទ: <u>888-999-2881</u>
2. តាមអនឡាញ: <u>www.publiccounsel.net/dlclu/intake</u>
3. តាមសំបុត្រប្រៃសណីយ៍ធម្មតា: Dookhan Case Intake<br>Drug Lab Crisis Litigation Unit<br>Committee for Public Counsel Services<br>7 Palmer St., Suite 302<br>Roxbury, MA 02119

B. **<u>បើប្រាក់ចំណូលរបស់លោក-អ្នកខ្ពស់ពេកហួសពីលក្ខណៈសម្បត្តិក្នុងការទទួលមេធាវីដែលគេតែងតាំងឱ្យ</u>**, លោក-អ្នកអាចជួលមេធាវីម្នាក់ដោយខ្លួនឯង។ បើលោក-អ្នកមិនទាន់មានមេធាវីនៅឡើយ លោក-អ្នកប្រហែលជាអាចរកមួយបានដោយទាក់ទងសមាគមន៍មេធាវីរដ្ឋម៉ាស្សាជូសេត្ស៍, សមាគមន៍មេធាវីក្រុងបស់ស្តុន, ឬក៏សេវាកម្មសមាគមន៍មេធាវីដែលគេជួយណែនាំជូន។

មិនថាឡើយប្រាក់ចំណូលរបស់លោក-អ្នកយ៉ាងណាទេ លោក-អ្នកអាចទូរស័ព្ទបណ្តាញបន្ទាន់ករណី Dookhan ។

## មានសំណួរ? ចូរទូរស័ព្ទទៅបណ្តាញបន្ទាន់!

បើលោក-អ្នកមានសំណួរអំពីអ្វីនៅក្នុងកញ្ចប់នេះ ឬបើលោក-អ្នកចង់ដឹងបន្ថែមពីរបៀបប្រើប្រាស់សិទ្ធិរបស់ខ្លួន ចូរទូរស័ព្ទទៅ <u>888-999-2881</u>។ បណ្តាញបន្ទាន់នេះបើកធ្វើការពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 9:30 ព្រឹកទៅម៉ោង 5:00 ល្ងាច។ ការទាក់ទងគឺជាការសម្ងាត់ 100% និងចាត់ចែងដោយបុគ្គលិកការិយាល័យមេធាវីការពារចុងចោទសាធារណៈ, CPCS ។

បើលោក-អ្នកប្រគល់សណ្ឋានឯកសារដែលដាក់ភ្ជាប់មកជាមួយទៅតុលាការរួចហើយៗ ពុំទាន់បានលឺពីមេធាវី ឬពីតុលាការក្នុងរយៈពេល 30 ថ្ងៃ សូមមេត្តាទូរស័ព្ទទៅបណ្តាញបន្ទាន់ដើម្បីឱ្យគេជួយ។

**សំរាប់ព័ត៌មានបន្ថែម:**

***888-999-2881***

***www.mass.gov/courts/druglab***

# Committee for Public Counsel Services

**( គណៈកម្មការសេវាកម្មសម្រាប់មេធាវីសាធារណៈ )**

*Drug Lab Crisis Litigation Unit*

( *អង្គភាពវិវាទវិបត្តិមន្ទីរពិសោធន៍គ្រឿងញៀន* )

*7 Palmer Street, Suite 302, Roxbury, MA 02119*

TELÉFONO: 617-445-7581 FAX: 617-427-1320

*ទូរស័ព្ទបន្ទាន់ករណី Dookhan: 888-999-2881*

មិថុនា 2017

ជូនចំពោះ ________________ :

លោក-អ្នកបានទទួលកញ្ចប់នេះ ដោយសារតែលោក-អ្នកមានការផ្តន្ទាទោសបទឧក្រិដ្ឋមួយដោយសារតែមានការក្លែងបន្លំរបស់អតីតគីមីវិទូមន្ទីរពិសោធន៍រដ្ឋ អានី្ន ដូក្ខាន ( Annie Dookhan) ។ យើងសរសេរមកលោក-អ្នកក្នុងនាមជាអ្នកការពារចុងចោទសាធារណៈដែលបានប្រឆាំងតវ៉ារកយុត្តិធម៌ជូនមនុស្សដែល ដូចជាលោក-អ្នកអញ្ចឹង ទទួលការផ្តន្ទាទោសដោយភាពក្រខ្វក់របស់ Dookhan ។ យើងសង្ឃឹមថា លិខិតនេះនឹងជួយឱ្យអ្នកសម្រេចចិត្តត្រូវធ្វើអ្វី នៅពេលនេះដែលអ្នកដឹងថា *លោក-អ្នក*មានការផ្តន្ទាទោសនោះ។

"កំណត់សំគាល់ពីសិទ្ធិ" នៅក្នុងកញ្ចប់នេះជំរាបលោក-អ្នកឱ្យដឹងថា លោក-អ្នកមានសិទ្ធិមានមេធាវីម្នាក់ជួយណែនាំ និងជាតំណាងដល់លោក-អ្នកក្នុងសំណុំរឿង Dookhan --ដោយមិនគិតថ្លៃ បើសិនជាលោក-អ្នកមិនអាចលៃលកជួលម្នាក់បាន។ យើងជំរុញឱ្យលោក-អ្នកប្រើប្រាស់សិទ្ធិនោះ ដោយទូរស័ព្ទទៅបណ្តាញសម្ងាត់របស់យើងតាមលេខ 888-999-2881។ ***លោក-អ្នកគ្មានអ្វីត្រូវខាតបង់ទេ*** ដោយជ្រើសយកជំហាននេះ។ នៅពេលដែលលោក-អ្នកសុំឱ្យមានមេធាវី លោក-អ្នកមិនបានសន្យាថានឹងទៅតុលាការដើម្បីដេញដោលការផ្តន្ទាទោសរបស់លោក-អ្នកដោយសារតែអ្នកស្រី Dookhan នោះទេ។ លោក-អ្នកនឹងអាចជួបជាមួយមេធាវីរបស់លោក-អ្នក និង ពិភាក្សាអំពីជម្រើសរបស់លោក-អ្នក មុនពេលដែលលោក-អ្នកសម្រេចចិត្ត ថាតើត្រូវទៅតុលាការ ឬអត់។ បើសិនជាលោក-អ្នកសម្រេចចិត្តថានឹងមិនទៅកាន់តុលាការទេ សំណុំរឿងរបស់លោក-អ្នកនឹងចប់ត្រឹមនេះ ហើយការផ្តន្ទាទោសដោយ Dookhan របស់លោក-អ្នក នឹងនៅបន្តទៅមុខទៀត។ ប្រសិនបើលោក-អ្នកសម្រេចចិត្តក្នុងការតវ៉ាដេញដោលការផ្តន្ទាទោស Dookhan របស់លោក-អ្នក, មេធាវីរបស់អ្នកនឹងដាក់ញ្ញត្តិស្នើឱ្យលុបចោលនៅក្នុងតុលាការ ដែលគេបានផ្តន្ទាទោសលោក-អ្នក ហើយលោក-អ្នកនឹងមានសវនាការនៅចំពោះមុខចៅក្រមយោងតាមញ្ញត្តិស្នើនោះ។

វាជាការសំខាន់គួរតែដឹងថា បើលោក-អ្នកជោគជ័យក្នុងញ្ញត្តិស្នើឱ្យលុបចោលការផ្តន្ទាទោសដោយទង្វើរបស់ Dookhan ***លោក-អ្នកនឹងមិនប្រឈមមុខនឹងការដាក់ទណ្ឌកម្មលើសពីអ្វីដែលលោក-អ្នកបានទទួលរួចហើយក្នុងសំណុំរឿងរបស់លោក-អ្នកឡើយ។*** បើការចោទប្រកាន់ក្នុងសំណុំរឿងរបស់លោក-អ្នកត្រូវកាត់បន្ថយ ឬជំរះចោល ការចោទប្រកាន់ពីដំបូងនោះនឹងមិនអាចត្រូវគេយកមកសារជាថ្មីបានឡើយ។ បើសិនជាលោក-អ្នកបានជាប់ឃុំរួចទៅហើយ នោះគេមិនអាចដាក់ឃុំលោក-អ្នកទៀតទេ សូម្បីតែមួយថ្ងៃទៀតក៏ទេដែរ។ ទាំងនេះក៏ដូចជាបញ្ហាក្រោមអាជ្ញាអង្កេត ( ប្រ៉ូបេស្សិន ) និងការពិន័យជាប្រាក់ដែរ--គេមិនអាចតម្រូវឱ្យលោក-អ្នកជាប់ក្រោមអាជ្ញាអង្កេត ឬបង់ពិន័យជាប្រាក់ទៀតឡើយ។

***តើលោក-អ្នកមានអ្វីខ្លះដែលត្រូវចំណេញដោយការដេញដោលការផ្តន្ទាទោស Dookhan របស់លោក-អ្នក?*** ចម្លើយវាអាស្រ័យលើកាលៈទេសៈរបស់លោក-អ្នក។ ការផ្តន្ទាទោសពីបទគ្រឿងញៀនតែងប្រឈមនឹងលទ្ធផលធ្ងន់ធ្ងរដោយឡែក និងយូរអង្វែងជាងការដាក់ទណ្ឌកម្មដែលត្រូវគេធ្វើឡើងនៅក្នុងតុលាការ។ លទ្ធផលទាំងនោះត្រូវបានគេហៅថា"ទណ្ឌកម្មដែលមើលមិនឃើញ" ហើយវាអាចធ្វើឱ្យមានការលំបាក ឬក៏ធ្វើឱ្យលោក-អ្នកមិនអាចរស់នៅដោយមានជីវិតដ៏ល្អប្រសើរទៅរួចបាន

ឡើយ។ ឧទាហរណ៍នានាដូចជា ចំណុចដែលការផ្តន្ទាទោសដោយសារគ្រឿងញៀននោះត្រូវគេដាក់ទណ្ឌកម្ម "ដែលមើលមិនឃើញ" បន្ថែមគឺ:

- ឥន្ទោប្រវេសន៍
- លំនៅដ្ឋាន
- អាជ្ញាប័ណ្ណដែលមានជំនាញវិជ្ជាជីវៈ និងការងារ
- ការប្រកបការងារជាទូទៅ
- ផលប្រយោជន៍សាធារណៈ
- ជំនួយហិរញ្ញវត្ថុសម្រាប់ការអប់រំថ្នាក់ខ្ពស់

លោក-អ្នកប្រហែលជាបានជួបប្រទះនូវបញ្ហាអស់នេះខ្លះរួចទៅហើយក្នុងឆាកជីវិតរបស់លោក-អ្នក។ បើដូចនោះមែន លុបចោលនូវការផ្តន្ទាទោសថ្នាំញៀន Dookhan របស់លោក-អ្នកប្រហែលជាអាចធ្វើឱ្យមានភាពខុសគ្នាមួយ។ សូម្បីតែប្រសិនបើលោក-អ្នកមិនបានជួបប្រទះបញ្ហាទាំងនេះនៅក្នុងពេលកន្លងមក, លុបចោកការផ្តន្ទាទោសថ្នាំញៀន Dookhan របស់លោក-អ្នកប្រហែលជាអាចផ្តល់នូវលទ្ធភាពថ្មីៗ សម្រាប់អនាគតរបស់លោក-អ្នកដែលប្រហែលជាមិនមានទេ បើគ្មានឱកាសនេះ។

មានហេតុផលមួយទៀតដែលលោក-អ្នកគួរតែពិចារណាពិភាក្សាជាមួយមេធាវីម្នាក់អំពីលទ្ធភាពនៃការលុបចោលការផ្តន្ទាទោសថ្នាំញៀន Dookhan នេះ៖ ***យុត្តិធម៌***។ ការផ្តន្ទាទោសរបស់លោក-អ្នកគឺអាស្រ័យតាមការក្លែងបន្លំដែលបានប្រព្រឹត្តិឡើងដោយភ្នាក់ងាររបស់រដ្ឋ។ លោក-អ្នកបានជាប់ឃុំ ឬជាប់ក្រោមអាជ្ញាអង្កេត ឬក៏ទាំងពីរហ្នឹង។ លោក-អ្នកមិនអាចយកមកវិញបាននូវសេរីភាពដែលបានបាត់បង់ទេ ប៉ុន្តែលោក-អ្នកអាចព្យាយាមលាងជម្រះខ្លួនឯងនូវការផ្តន្ទាទោសដែលមិនស្អាតស្អំ។ តាមការដកពិសោធន៍របស់យើងដែលការពារបុគ្គលដែលត្រូវគេផ្តន្ទាទោសក្នុងករណី Dookhan យើងបានឃើញថា ជាច្រើននាក់យល់ថា វាជាការធូរស្រាលក្នុងចិត្តចំពោះការប្រឆាំងតវ៉ាឱ្យគេលុបចោលនូវការផ្តន្ទាទោសដែលសម្រេចទៅដោយភាពអយុត្តិធម៌។

បើសិនជាមានសំណួរអំពីអ្វីដែលយើងខ្ញុំបានសរសេរ ឬបញ្ហាផ្សេងទៀតនៅក្នុងកញ្ចប់នេះ យើងជំរុញឱ្យលោក-អ្នកទូរស័ព្ទទៅបណ្តាញបន្ទាន់តាម **888-999-2881**។ បើលោក-អ្នកត្រៀមខ្លួនស្រេចហើយដើម្បីសុំឱ្យគេចាត់តាំងមេធាវីម្នាក់មកពិភាក្សា និងធ្វើជាតំណាងលោក-អ្នក ឬក៏លោក-អ្នកមានសំណួរអ្វី ថាតើគួរតែពិភាក្សាជាមួយមេធាវីម្នាក់ឬអត់ យើងក៏ជំរុញឱ្យលោក-អ្នកទូរស័ព្ទទៅបណ្តាញបន្ទាន់ដែរ។ លោក-អ្នកក៏អាចស្នើសុំឱ្យគេជួយដោយសរសេរជាលាយលក្ខណ៍អក្សរមកយើងខ្ញុំតាមអាស័យដ្ឋានខាងលើ ឬដោយចូលក្នុងគេហទំព័រនេះ និងស្នើសុំសួរតាមបណ្តាញអនឡាញ: www.publiccounsel.net/dlclu/intake ។

យើងប្តេជ្ញាថានឹងប្រឆាំងតវាដើម្បីយុត្តិធម៌សម្រាប់បុគ្គលជាច្រើនដែលត្រូវបានរងគ្រោះដោយការក្លែងបន្លំរបស់ Dookhan និងការធ្វេសប្រហែសរបស់រដ្ឋនៅមន្ទីរពិសោធន៍ដែលគាត់បានធ្វើការ។ យើងរង់ចាំស្តាប់ដំណឹងពីលោក-អ្នក។

ដោយសេចក្តីរាប់អាន,

ណានស៊ី ខាបប្លេន (Nancy J. Caplan)

មេធាវីទទួលខុសត្រូវ